# ស្រឡាញ់ម្ដាយរបស់នាង

*ដោយ អេលែន អេស ដាល់ថុន*
*ប្រធានយុវនារីទូទៅ*

គ្មានពាក្យពេចន៍ណាដែលអាចពិពណ៌នានូវឱកាសដ៏ពិសិដ្ឋ នៅពេលដែលឪពុកក្មេងខ្ចីម្នាក់បីកូនស្រីរបស់ខ្លួននៅក្នុងដៃជាលើកដំបូងនោះទេ ។ ឆ្នាំនេះ កូនប្រុសបីនាក់របស់យើង បានក្លាយជាឪពុកថ្មីថ្មោងរបស់កូនស្រីពួកគេ ។ នៅពេលដែល ខ្ញុំមើល ចន កូនប្រុសដ៏រឹងមាំរបស់យើង បីកូនស្រីដំបូងរបស់គេនៅក្នុងដៃ ដោយសម្លឹងទៅកូនស្រីនោះជាមួយនឹងកែវភ្នែកស្រទន់ក្នុងក្ដីគោរព ហើយបន្ទាប់មក គេបានមើលមកខ្ញុំដោយឥរិយាបទដែលហាក់ដូចជាចង់សួរថា — « តើកូននឹងចិញ្ចឹមបីបាច់កូនស្រីម្នាក់យ៉ាងដូចម្ដេចទៅ ? »

នៅព្រឹកនេះ ខ្ញុំសូមនិយាយទៅកាន់កូនប្រុសរបស់យើង និងទៅកាន់ឪពុកទាំងឡាយ ។ តើឪពុកម្នាក់ អាចចិញ្ចឹមបីបាច់កូនស្រីឲ្យបានល្អនៅក្នុងពិភពលោក ដ៏មានគ្រោះថ្នាក់យ៉ាងច្រើននេះ បានដោយរបៀបណា ? ចម្លើយត្រូវបានផ្ដល់ឲ្យដោយការបង្រៀនពីព្យាការីរបស់ព្រះអម្ចាស់ ។ វាគឺជាចម្លើយដ៏សាមញ្ញមួយ ហើយវាជាការពិត — « អ្វីដែលសំខាន់បំផុតដែលឪពុកម្នាក់ អាចធ្វើសម្រាប់ [ កូនស្រី ] របស់គេ គឺស្រឡាញ់ម្ដាយ [ របស់នាង ] » ។[1] តាមរបៀបដែលអ្នកស្រឡាញ់ម្ដាយរបស់នាង នោះអ្នកនឹងបង្រៀនកូនស្រីរបស់អ្នក អំពីភាពទន់ភ្លន់ ភក្ដីភាព ការគោរព ការអាណិតអាសូរ និងការពលិកម្ម ។ នាងនឹងរៀនពីគំរូរបស់អ្នកដោយរំពឹងទុកនូវអ្វីដែលចង់បាន និងគុណសម្បត្តិអ្វីខ្លះពីយុវជនដើម្បីស្វែងរកប្ដីឬប្រពន្ធម្នាក់នាពេលអនាគត ។ អ្នកអាចបង្ហាញដល់កូនស្រីរបស់អ្នកតាមរយៈសេចក្ដីស្រឡាញ់ និងការគោរពរបស់អ្នកមានចំពោះភរិយាអ្នក ថានាងរំពឹងចង់រៀបការជាមួយនរណាម្នាក់ដែលចេះស្រឡាញ់ និងគោរពដល់នាង ។ គំរូរបស់អ្នកនឹងបង្រៀនកូនស្រីរបស់អ្នកពីតម្លៃនៃភាពជាស្ត្រី ។ អ្នកកំពុងតែបង្ហាញថា នាងគឺជាបុត្រីនៃព្រះវរបិតាសួគ៌ ដែលទ្រង់ស្រឡាញ់នាង ។

សូមស្រឡាញ់ម្ដាយរបស់នាងឲ្យច្រើនបំផុត ដើម្បីធ្វើឲ្យអាពាហ៌ពិពាហ៌របស់អ្នក គឺនៅសេឡេស្ទាល ។ ការរៀបអាពាហ៌ពិពាហ៌នៅព្រះវិហារបរិសុទ្ធសម្រាប់ពេលឥឡូវ និងសម្រាប់ភាពអស់កល្បជានិច្ច គឺសក្ដិសមសម្រាប់ការខិតខំដ៏មហិមារបស់អ្នក និងមានសារៈសំខាន់បំផុត ។ គ្រាន់តែបន្ទាប់ពីនីហ្វៃបានសង់ព្រះវិហារបរិសុទ្ធនៅក្នុងទីរហោស្ថានរួច គាត់បាននិយាយថា ៖ «ហើយ. . .ពួកយើងបានរស់នៅតាមរបៀបនៃសុភមង្គល » «របៀបនៃសុភមភង្គល » គឺត្រូវបាននៅក្នុងព្រះវិហារបរិសុទ្ធ ។ វាគឺជាការរក្សាសេចក្ដីសញ្ញា ។ ចូរកុំឲ្យមានឥទ្ធិពលណាមកគ្របដណ្ដប់លើជីវិត ឬគេហដ្ឋានរបស់អ្នក ដែលនឹងបណ្ដាលឲ្យអ្នកទម្លាក់សេចក្ដីសញ្ញា ឬការប្ដេជ្ញាចិត្តរបស់អ្នក ចំពោះភរិយា និងក្រុមគ្រួសារឡើយ ។

នៅក្នុងថ្នាក់យុវនារី យើងកំពុងជួយកូនស្រីអ្នកយល់ពីអត្តសញ្ញាណរបស់នាង ក្នុងនាមជាបុត្រីនៃព្រះ និងពីសារៈសំខាន់នៃការបន្តមានគុណធម៌ និងមានភាពស័ក្ដិសមដើម្បីទទួលពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ និងការរៀបអាពាហ៍ពិពាហ៍នៅព្រះវិហារបរិសុទ្ធមួយ ។ យើងកំពុងតែបង្រៀនកូនស្រីរបស់អ្នកពីសារៈសំខាន់នៃការធ្វើ និងការរក្សាសេចក្ដីសញ្ញាពិសិដ្ឋ ។ យើងកំពុងតែបង្រៀននាងឲ្យតាំងចិត្តពីពេលឥឡូវនេះ ដើម្បីរស់នៅតាមដូច្នេះនាងអាចមានភាពស័ក្ដិសមជានិច្ចដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធ ហើយពុំបណ្ដោយឲ្យមានអ្វីមួយមករំខាន ពន្យាពេល ឬធ្វើឲ្យនាងមិនមានភាពស័ក្ដិសមសម្រាប់គោលដៅនោះបាន ។ គំរូរបស់អ្នកក្នុងនាមជាឪពុករបស់នាង គឺមានឥទ្ធិពលខ្លាំងជាងពាក្យសំដីខ្លាំងៗរបស់យើងទៅទៀត ។ យុវនារីទាំងឡាយ ព្រួយបារម្ភពីឪពុករបស់គេ ។

មានពាក្យសំដីជាច្រើននិយាយថា បំណងប្រាថ្នាដ៏ធំជាងគេបំផុតរបស់ពួកគេ គឺដើម្បីរួមរស់ជាក្រុមគ្រួសាររហូតដល់អស់កល្បជានិច្ច ។ ពួកនាងចង់ឲ្យអ្នកនៅទីនោះ នៅពេលដែលពួកនាងទៅព្រះវិហារបរិសុទ្ធ ឬរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមនៅជិតស្និទ្ធនឹងកូនស្រីរបស់អ្នក ហើយជួយរៀបចំនាង ហើយបន្តមានភាពស័ក្ដិសមដើម្បីទៅព្រះវិហារបរិសុទ្ធ ។ នៅពេលដែលនាងមានអាយុ 12 ឆ្នាំ សូមនាំនាងទៅព្រះវិហារបរិសុទ្ធជាមួយអ្នកឲ្យបានញឹកញាប់ ដើម្បីធ្វើពិធីបុណ្យជ្រមុជទឹក សម្រាប់បុព្វការីជនរបស់អ្នក និងអ្នកដទៃទៀត ។ កូនស្រីរបស់អ្នក នឹងចងចាំអនុស្សាវរីយ៍នេះជារៀងរហូត ។

វប្បធម៌ដ៏ពេញនិយមសព្វថ្ងៃនេះកំពុងព្យាយាមបំផ្លាញយ៉ាងឃើតៗ ពីតួនាទីដ៏នៅអស់កល្បជានិច្ចរបស់អ្នក ក្នុងនាមជាលោកអយ្យកោ និងជាឪពុក ហើយកាត់បន្ថយតួនាទីដ៏មានសារៈសំខាន់របស់អ្នកចេញ ។ អ្វីៗទាំងនេះត្រូវបានផ្ដល់ឲ្យអ្នកដោយ « គោលដៅនៃព្រះ » ហើយក្នុងនាមជាឪពុកអ្នក « ត្រូវបានចាត់ឲ្យធ្វើជាអ្នកដឹកនាំនៅក្នុងគ្រួសារ [ របស់អ្នក ] ដោយក្ដីស្រឡាញ់ និងសេចក្ដីសុចរិត ហើយមានភារកិច្ចក្នុងការផ្គត់ផ្គង់តម្រូវការក្នុងជីវិត ព្រមទាំងការពារក្រុមគ្រួសារ [ របស់អ្នក ] » ។[3]

ឪពុក មានអត្ថន័យថាជាអ្នកគាំពារគេហដ្ឋាន ភរិយា និងកូនចៅរបស់អ្នក ។ នៅសព្វថ្ងៃនេះ « វាមិនមែនជារឿងងាយស្រួលទេ ក្នុងការការពារក្រុមគ្រួសារមួយប្រឆាំងនឹងបំណងអាក្រក់របស់អាក្សទាំងក្នុងគំនិត និងវិញ្ញាណ [របស់ពួកគេ ] ...។ ឥទ្ធិពលទាំងនេះ អាចហូរចូលក្នុងគេហដ្ឋានរបស់អ្នកដោយងាយ ។ សាតាំង គឺ [ ឆ្លាតខ្លាំងណាស់ ] ។ វាពុំចាំបាច់បើកទ្វារចូលនោះទេ » ។[4]

ឪពុកទាំងឡាយ អ្នកត្រូវតែធ្វើជាអ្នកគាំពារដល់គុណធម៌ ។ « អ្នកកាន់បព្វជិតភាព គឺជាគុណធម៌ ។ ឥរិយាបទនៃគុណធម៌បង្ហាញថា [ អ្នកមាន ] គំនិតបរិសុទ្ធ និងទង្វើស្អាតស្អំ...។ គុណធម៌ គឺជា...បុគ្គលិក     លក្ខណៈចេះគោរពព្រះ... ។ [ គុណធម៌ ] គឺស្រដៀងគ្នាទៅនឹងបរិសុទ្ធភាព » ។ [5] គុណតម្លៃរបស់យុវនារី គឺជាបុគ្គលិកលក្ខណៈដូចជាព្រះគ្រីស្ទ ដែលរួមទាំងតម្លៃនៃគុណធម៌ ។ ឥឡូវនេះយើងសូមអំពាវនាវដល់អ្នកឲ្យចូលរួមជាមួយយើងនៅក្នុងការដឹកនាំពិភពលោកឲ្យត្រឡប់ទៅរកតម្លៃនៃគុណធម៌វិញ ។ ដើម្បីធ្វើដូច្នោះបាន អ្នក « ត្រូវអនុវត្តឲ្យមានគុណធម៌ និងបរិសុទ្ធភាព » [6] តាមរយៈការកំចាត់ចោលនូវអ្វីៗដែលអាក្រក់ និងមិនខ្ទាប់ខ្លួនពីជីវិតរបស់យើង ជាមួយនឹងអ្នកដែលកាន់បព្វជិតភាពបរិសុទ្ធនៃព្រះ ។ « សូមឲ្យគុណធម៌តុបតែងគំនិតអ្នក ដោយឥតឈប់ឈរឡើយ ខណៈនោះអ្នកនឹងមានចិត្តក្លាហានឡើង នៅចំពោះវត្តមាននៃព្រះ ហើយ... ព្រះវិញ្ញាណបរិសុទ្ធ នឹងទៅជាគូកនអ្នកជានិច្ច » ។[7] សូមប្រយ័ត្នប្រយែងចំពោះអ្វីដែលអ្នកមើលនៅក្នុងព័ត៌មាន ដែលបានបោះពុម្ពវាចេញមក ។ គុណធម៌ផ្ទាល់ខ្លួនរបស់អ្នក នឹងធ្វើជាគំរូដល់កូនស្រីអ្នក ហើយកូនប្រុសអ្នកក៏ដូច្នោះដែរ ដើម្បីមានកម្លាំង និងសីលធម៌នៃសេចក្ដីក្លាហានដ៏ពិតប្រាកដ ។ តាមរយៈការមើលខុសត្រូវលើគុណធម៌នៅក្នុងជីវិត គេហដ្ឋាន និងនៅក្នុងជីវិតនៃកូនចៅរបស់អ្នក នោះអ្នកកំពុងបង្ហាញដល់ភរិយា និងកូនស្រីរបស់អ្នកថា តើសេចក្ដីស្រឡាញ់ពិតប្រាកដវាបែបណា ។ បរិសុទ្ធភាពផ្ទាល់ខ្លួនអ្នក នឹងផ្ដល់អំណាចដល់អ្នក ។

អ្នកគឺជាអ្នកគាំពារដល់កូនស្រីរបស់អ្នក លើសពីស្មារតីស្របច្បាប់នៃពាក្យនោះ ។ សូមធ្វើជាផ្នែកដ៏សកម្មនៅក្នុងជីវិតនៃកូនស្រីរបស់អ្នក ។ សូមឲ្យនាងបានស្គាល់បទដ្ឋាន ការរំពឹងទុក សេចក្ដីសង្ឃឹម និងក្ដីសុបិនរបស់អ្នកសម្រាប់ភាពជោគជ័យ និងសុភមង្គលនាង ។ សូមនិយាយជាមួយនាងសូមរៀនស្គាល់មិត្តភក្តិរបស់នាង ហើយនៅពេលវេលាមកដល់ សូមរៀនស្គាល់សង្សាររបស់នាង ។ សូមជួយនាងយល់ពីសារៈសំខាន់នៃការអប់រំ ។ សូមជួយនាងយល់ពីគោលការណ៍នៃភាពសមរម្យ គឺជាការការពារ ។ សូមជួយនាងជ្រើសតន្ត្រី និងសារព័ត៌មានដែលអញ្ជើញព្រះវិញ្ញាណ និងស្របតាមអត្តសញ្ញាណដ៏ទេវភាពរបស់នាង ។ សូមធ្វើជាផ្នែកដ៏សកម្មមួយនៅក្នុងជីវិតរបស់នាង ។ ហើយ កាលដែលនាងមានវ័យជំទង់ ប្រសិនបើនាងចេញទៅដើរលេងជាគូ រួចមិនត្រឡប់មកផ្ទះទាន់ម៉ោង សូមទៅទទួលនាងមកផ្ទះ ។ នាងនឹងជំទាស់ ហើយប្រាប់អ្នកថា អ្នកបំផ្លាញជីវិតខាងសង្គមរបស់នាង ប៉ុន្តែក្នុងចិត្តនាង នាងនឹងដឹងថាអ្នកស្រឡាញ់នាង ហើយថាអ្នកខ្វល់ខ្វាយគ្រប់គ្រាន់ល្មមដើម្បីធ្វើជាអ្នកមើលថែរនាង ។

អ្នកពុំមែនជាបុរសធម្មតានោះទេ ។ ពីព្រោះតែភាពខុសគ្នានៅក្នុងជីវិតមុនផែនដីនេះ នោះអ្នកមានគុណសម្បត្តិ ដើម្បីធ្វើជាអ្នកដឹកនាំ និងដើម្បីទទួលអំណាចនៃបព្វជិតភាព ។ ពេលនោះអ្នកបង្ហាញនូវ « សេចក្ដីជំនឿដ៏លើសលប់ និងកិច្ចការដ៏ល្អទាំងឡាយ » ហើយអ្នកនៅទីនេះ ពេលនេះ ដើម្បីធ្វើកិច្ចការដូចគ្នានោះដែរ ។ [8] បព្វជិតភាពអ្នក ញែកអ្នកចេញ ។ នៅប៉ុន្មានសប្ដាហ៍ទៀត កូនប្រុសទាំងបីនាក់របស់យើង នឹងធ្វើពិធីដាក់ឈ្មោះ និងផ្ដល់ពរជ័យដល់កូនស្រីរបស់ពួកគេ ។ ខ្ញុំសង្ឃឹមថា ការណ៍នេះ នឹងក្លាយទៅជាពរជ័យបព្វជិតភាពមួយ ក្នុងចំណោមពរជ័យជាច្រើន ដែលកូនទទួលបានពីឪពុករបស់ខ្លួន ពីព្រោះនៅក្នុងពិភពលោកដែលពួកគេធំឡើង ពួកគេនឹងត្រូវការពរជ័យនោះ ។ កូនស្រីរបស់អ្នកនឹងលើកដំកើងបព្វជិតភាព និងប្ដេជ្ញាចិត្តក្នុងចិត្តរបស់នាងថា នេះគឺជាអ្វីដែលនាងចង់បាននៅក្នុងគេហដ្ឋាន និងក្រុមគ្រួសារនាពេលអនាគតរបស់នាង ។ សូមចងចាំជានិច្ចថា « សិទ្ធិទាំងឡាយនៃបព្វជិតភាព គឺមានជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ » ហើយអាច «  ត្រួតត្រា... ដោយគោលការណ៍នៃសេចក្ដីសុចរិតប៉ុណ្ណោះ » ។ [9]

ឪពុកទាំងឡាយ អ្នកគឺជាវីរៈបុរសកូនស្រីអ្នក ។ ឪពុករបស់ខ្ញុំគឺជាវីរៈបុរសរបស់ខ្ញុំ ។ ខ្ញុំធ្លាប់អង្គុយនៅលើកាំជណ្ដើរផ្ទះរបស់យើងជារៀងរាល់យប់រង់ចាំគាត់ត្រឡប់មកផ្ទះវិញ ។ គាត់នឹងលើកខ្ញុំឡើង ហើយគ្រវីខ្ញុំ រួចគាត់ដាក់ខ្ញុំចុះឲ្យឈរនៅលើស្បែកជើងដ៏ធំរបស់គាត់ ហើយគាត់រាំជាមួយខ្ញុំនៅក្នុងផ្ទះ ។ ខ្ញុំចូលចិត្តឱកាសនៃព្យាយាមដើរតាមជើងរបស់គាត់ ។ ខ្ញុំនៅតែចូលចិត្ត ។

តើអ្នកដឹងថាទីបន្ទាល់របស់អ្នកមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើកូនស្រីរបស់អ្នកឬទេ?  ខ្ញុំដឹងថាឪពុករបស់ខ្ញុំមានទីបន្ទាល់ ។ ខ្ញុំដឹងថាគាត់ស្រឡាញ់ព្រះអម្ចាស់ ។ ហើយដោយសារតែឪពុករបស់ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ខ្ញុំក៏ស្រឡាញ់ទ្រង់ដែរ ។ ខ្ញុំដឹងថាគាត់ព្រួយប្រារម្ភពីស្ដ្រីមេម៉ាយ ពីព្រោះគាត់ចំណាយពេលវិសាមកាលរបស់គាត់ដើម្បីលាបថ្នាំផ្ទះឲ្យស្ដ្រីមេម៉ាយដែលរស់នៅជិតផ្ទះ ។ ខ្ញុំគិតថា នោះគឺជាវិសាមកាលដ៏អស្ចារ្យបំផុតដែលក្រុមគ្រួសាររបស់យើងមិនធ្លាប់មាន ពីព្រោះគាត់បានបង្រៀនខ្ញុំឲ្យចេះលាបថ្នាំ ! អ្នកនឹងប្រទានពរដល់ជីវិតកូនស្រីអ្នកជាច្រើនឆ្នាំខាងមុខទៀត ប្រសិនបើអ្នកស្វែងរកវិធីដើម្បីចំណាយពេលជាមួយនឹងនាង និងដើម្បីចែកចាយទីបន្ទាល់ជាមួយនាង ។

នៅក្នុងព្រះគម្ពីរមរមន អ័ប៊ីសត្រូវបានផ្លាស់ប្រែចិត្តជឿដោយការចែកចាយរបស់ឪពុកនាងនូវការនិមិត្តដ៏អស្ចារ្យរបស់គាត់ ។ អស់រយៈពេលជាច្រើនឆ្នាំមក នាងបានរក្សាទីបន្ទាល់នៅក្នុងចិត្តរបស់នាង ហើយរស់នៅដោយសុចរិតនៅក្នុងសង្គមដ៏ទុច្ចរិត ។ បន្ទាប់ពី ពេលវេលាបានមកដល់ នៅពេលដែលទីបន្ទាល់មិនអាចលាក់ទុកក្នុងចិត្តបាន នាងបានចេញពីផ្ទះមួយទៅផ្ទះមួយ ដើម្បីចែកចាយទីបន្ទាល់របស់នាង និងចែកចាយពីអព្ភូតហេតុដែលនាងបានធ្វើជាសាក្សីនៅក្នុងសាលក្រមរបស់ស្ដេច ។ អំណាចនៃការផ្លាស់ប្រែចិត្តជឿ និងទីបន្ទាល់របស់ អ័ប៊ីស គឺជាឧបករណ៍ដើម្បីផ្លាស់ប្ដូរសង្គមទាំងមូល ។ ប្រជាជនដែលបានឮទីបន្ទាល់របស់នាង ក្លាយទៅជាមនុស្សដែល « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ [ ហើយ ] ពុំបោះបង់ចោលសាសនាឡើយ » ហើយកូនប្រុសរបស់ពួកគេ បានក្លាយជាទ័ពកម្លោះ ![10]

ដូចជានៅក្នុងទំនុកដំកើងមួយបទ សរសេរថា « ក្រោកឡើង ឱ! បុរសទាំងឡាយរបស់ព្រះអើយ! »[11] នេះគឺជាការអំពាវនាវដល់អ្នក ឱ បុរសទាំងឡាយដែលកាន់បព្វជិតភាពដ៏បរិសុទ្ធនៃព្រះ ។ សូមឲ្យមានពាក្យនិយាយពីអ្នក ដូចដែលបាននិយាយពីមេទ័ពមរ៉ូណៃថា ៖

« [គាត់] ជាបុរសម្នាក់ដ៏មានកម្លាំង ហើយខ្លាំងក្លា... ជាមនុស្សម្នាក់ដែលប្រកបទៅដោយការយល់ដឹងដ៏ឥតខ្ចោះ... ជាមនុស្សម្នាក់នៅក្នុងសេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ... ។ បើសិនជាមនុស្សទាំងអស់ ដែលធ្លាប់រស់នៅ ហើយកំពុងរស់នៅ ហើយនឹងរស់នៅដូចមរ៉ូណៃ មើលចុះ អំណាចទាំងឡាយរបស់ស្ថាននរកនឹងត្រូវញ័ររន្ធត់រហូតតទៅ... អារក្សនឹងគ្មានអំណាចទៅលើចិត្តនៃកូនចៅមនុស្សឡើយ » ។[12]

បងប្អូនប្រុស ឪពុក និងយុវជនទាំងឡាយអើយ « សូមមានភក្ដីភាពនឹងរាជដែលមាននៅក្នុងអ្នក » ។[13]

បើដូច្នេះ តើអ្នកនឹងចិញ្ចឹមកូនស្រីដោយរបៀបណា ? ចូរស្រឡាញ់ម្ដាយរបស់នាង ។ សូមដឹកនាំក្រុមគ្រួសាររបស់អ្នកទៅព្រះវិហារបរិសុទ្ធ សូមមើលថែគុណធម៌ និងលើកដំកើងដល់បព្វជិតភាពរបស់អ្នក ។ ឪពុកទាំងឡាយ អ្នកត្រូវបានទុកចិត្តមកពីព្រះវរបិតាសួគ៌ ជារាជានៃកូនស្រីរបស់យើង ។ ពួកគេគឺជាគុណធម៌ និងជម្រើស ។ វាគឺជាការអធិស្ឋានរបស់ខ្ញុំ សូមឲ្យអ្នកនឹងគាំពារដល់ពួកគេ ពង្រឹងពួកគេ ធ្វើជាគំរូនៃគុណធម៌ ហើយបង្រៀនពួកគេឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ — ត្បិតទ្រង់នៅមានព្រះជន្មរស់ ! នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. ដាវីឌ អូ មិកឃេ នៅក្នុង Theodore Hesbourgh, *Reader's Digest ខែ មករា ឆ្នាំ* 1963 ទំព័រ 25 សូមមើលផងដែរ *Richard Evans' Quote Book* (ឆ្នាំ 1971) ទំព័រ 11 ។
2. នីហ្វៃទី 2 5:27 ។
3. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភព លោក » លីអាហូណា និង and *Ensign ខែ វិច្ឆិកា ឆ្នាំ* 2010 ទំព័រ 129 ។
4. A. Theodore Tuttle « The Role of Fathers » *Ensign* ខែ មករា ឆ្នាំ 1974 ទំព័រ 67 ។
5. អែសរ៉ា ថាហ្វ បែនសឹន « Godly Characteristics of the Master » *Ensign ខែ វិច្ឆិកា ឆ្នាំ* 1986 ទំព័រ 46 ។
6. គោលលទ្ធិ និងសេចក្ដីសញ្ញា 46:33 ។
7. គោលលទ្ធិ និងសេចក្ដីសញ្ញា 121:45, 46 ។
8. អាលម៉ា 13:3 សូមមើលផងដែរខទី 2 ។
9. គោលលទ្ធិ និងសេចក្ដីសញ្ញា 121:36 ។
10. អាលម៉ា 23:6 សូមមើលផងដែរ អាលម៉ា 19:16–17; 53 ។
11. « Rise Up, O Men of God » *Hymns,* no. 323 ។
12. អាលម៉ា 48:11, 13, 17 ។
13. ហារ៉ូល ប៊ី លី « Be Loyal to the Royal within You » នៅក្នុង *Speeches of the Year: BYU Devotional and Ten-Stake Fireside Addresses 1973* (ឆ្នាំ 1973 ) ទំព័រ 101 ។